៤-វរសេនីយ៍ឯក ង្វៀន អាញ់យុង (NGUYEN ANH DUNG) ប្រធានអនុព័ន្ធយោធាវៀតណាម ប្រចាំនៅកម្ពុជា
៥-វរសេនីយ៍ឯក ផាម ង៉ុកអាញ់ (PHAM NGOC ANH) នាយកគ្រឹះស្ថានគីមី និងបរិស្ថាន

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គលេខាធិការនៃអាជ្ញាធរជាតិអាវុធគីមី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៥៦៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គលេខាធិការនៃអាជ្ញាធរជាតិអារុធគីមី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកវរសេនីយ៍ត្រី **ខិម ផារិន** អត្តលេខ ០៣៤០០៨ ជំនួយការផ្ទាល់ ឧត្តមសេនីយ៍ឯក ហេង វុទ្ធី អគ្គលេខាធិការរងអាជ្ញាធរជាតិអារុធគីមី ដែលមានស្នាដៃល្អក្នុងការចូលរួមជួយឧបត្ថម្ភសំភារៈដល់អាជ្ញាធរជាតិអារុធគីមី កន្លងមក ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការនៃអាជ្ញាធរជាតិអារុធគីមី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៥៤៣.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គលេខាធិការនៃអាជ្ញាធរជាតិអាវុធគីមី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃអាជ្ញាធរជាតិអាវុធគីមី ចំនួន០៣រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាងអគារវិទ្យាស្ថានស្រាវជ្រាវ និងពិសោធន៍សារធាតុអាវុធគីមី ក្នុងអាជ្ញាធរជាតិអាវុធគីមី កន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ

-វរសេនីយ៍ឯក ភាំង សុខគួច អត្តលេខ ០០២០៦៣ នាយការិយាល័យសង្គ្រោះ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ

១-លោក ទៀច សារ៉ាត់ ជំនួយការ

២-លោក ហូ សុខរចនា ជំនួយការ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គលេខាធិការនៃអាជ្ញាធរជាតិអាវុធគីមី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥៥៤ អនក្រ.គក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូននាយទាហាន នាយទាហានរង កងវិស្វកម្មលេខ៦០៣ មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាពបោសសំអាតមីន និងកាកសំណល់សង្គ្រាម ចំនួន ៨៨ រូប ដែលមានស្នាដៃក្នុងការបំពេញភារកិច្ចបេសកកម្មសន្តិភាព របស់អង្គការសហប្រជាជាតិ នៅប្រទេសលីបង់ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ

១-ឧត្តមសេនីយ៍ត្រី **គង់ តារុណា** អត្តលេខ ០០៣៨៨២ មន្ត្រីសេនាធិការ កងវិស្វកម្មលេខ៦០៣

២-វរសេនីយ៍ឯក **ព្រឹម អូ** អត្តលេខ ០២០៨៤៣ នាយទាហានគាំទ្រថ្នាក់ជាតិ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

១-ឧត្តមសេនីយ៍ត្រី **ម៉ត វណ្ណឌុន** អត្តលេខ ០១៩៧៦២ បុគ្គលិកពេទ្យ

២-វរសេនីយ៍ទោ **អ៊ិន ចាន់ណា** អត្តលេខ ០២០០៥៥ នាយទាហានគាំទ្រថ្នាក់ជាតិ

p

៣-វរសេនីយ៍ទោ	**ផល**	**ស៊ីមុត**	អត្តលេខ ០៦៨៧០៣	ប្រធានផ្នែកគ្រឿងចក្រ បោសសំអាតមីន
៤-វរសេនីយ៍ទោ	**សេង**	**តេងសេរី**	អត្តលេខ ០៤៨៥២៣	នាយទាហានសម្របសម្រួល
៥-វរសេនីយ៍ទោ	**អ៊ុច**	**សុឃឿន**	អត្តលេខ ០៣១៧៩១	នាយករងពេទ្យកំរិត១
៦-វរសេនីយ៍ទោ	**ម៉ាយ**	**ទឹមចិន្តា**	អត្តលេខ ០៣១៥០៧	នាយកពេទ្យកំរិត១
៧-អនុសេនីយ៍ទោ	**ឈុក**	**សារ៉ាយ**	អត្តលេខ ២០០៧៨២	មេបញ្ជាការកងអនុសេនាតូច បោសសំអាតមីននិងកំទេចគ្រឿងផ្ទុះ

គ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ

១-ឧត្តមសេនីយ៍ត្រី	**ឡេង**	**វណ្ណា**	អត្តលេខ ០១៩៣៥០	ជំនួយការត្រួតពិនិត្យគុណភាព
២-វរសេនីយ៍ឯក	**តូង**	**សុតារៈ**	អត្តលេខ ១៦២៤២៣	មេបញ្ជាការរងកងវិស្វកម្មលេខ៦០៣
៣-វរសេនីយ៍ឯក	**ស៊ិន**	**ឌន**	អត្តលេខ ០១៧៦៣៥	ជាងសំណង់
៤-វរសេនីយ៍ទោ	**តូង**	**វឌ្ឍនា**	អត្តលេខ ០៤៧៩៣០	ជំនួយការវិទ្យុទាក់ទង
៥-វរសេនីយ៍ទោ	**អ៊ិន**	**សារ៉ែន**	អត្តលេខ ០២៧១២៨	បុគ្គលិកបោកអ៊ុត
៦-វរសេនីយ៍ទោ	**ជា**	**ចន្ធា**	អត្តលេខ ០១៧៥៩៥	បុគ្គលិកកំទេចគ្រឿងផ្ទុះ
៧-វរសេនីយ៍ទោ	**កង**	**ឌីណា**	អត្តលេខ ០២៧៣៣១	ប្រធានក្រុមគ្រឿងចក្រ បោសសំអាតមីន
៨-វរសេនីយ៍ទោ	**ស៊ាង**	**សុខឈន**	អត្តលេខ ០៤៥៨៤៨	ប្រធានផ្នែកគ្រឿងចក្រ បោសសំអាតមីន
៩-វរសេនីយ៍ទោ	**គីម**	**ធី**	អត្តលេខ ០១៦៩០០	ជំនួយការទូទៅ
១០-វរសេនីយ៍ទោ	**ពៅ**	**ផនសុផារ៉ា**	អត្តលេខ ០២៧២០៤	ជំនួយការហិរញ្ញវត្ថុ
១១-វរសេនីយ៍ទោ	**មួន**	**សុខា**	អត្តលេខ ០២១៧៤៨	ជំនួយការស្រាវជ្រាវ
១២-វរសេនីយ៍ទោ	**ខៀង**	**សេដ្ឋា**	អត្តលេខ ០៤៧០៩៧	ជាងជួសជុល
១៣-វរសេនីយ៍ទោ	**សុខ**	**ស៊ីណាន**	អត្តលេខ ០៤៥៨៤៣	ប្រធានក្រុមបោសសំអាតមីន
១៤-វរសេនីយ៍ត្រី	**កុយ**	**រ៉ា**	អត្តលេខ ០១៩៨២៤	បុគ្គលិកពេទ្យ
១៥-វរសេនីយ៍ត្រី	**អែម**	**មូរី**	អត្តលេខ ០២៧២៩៨	បុគ្គលិកបើកបររថយន្ត
១៦-វរសេនីយ៍ត្រី	**សំរិទ្ធ**	**ចន្ថា**	អត្តលេខ ០២២២២១	បុគ្គលិកបើកបរគ្រឿងចក្រ
១៧-វរសេនីយ៍ត្រី	**ហ៊ួរ**	**ណារត**	អត្តលេខ ០៣៣៩៧២	បុគ្គលិកបើកបរគ្រឿងចក្រ
១៨-វរសេនីយ៍ត្រី	**តិន**	**សុភ័ក្ត្រ**	អត្តលេខ ០៤៧៧៥៥	ប្រធានក្រុមសន្តិសុខ
១៩-វរសេនីយ៍ត្រី	**អ៊ិន**	**សុដ្ឋាវី**	អត្តលេខ ២០០០៧២	ប្រធានផ្នែកស្ថាបនាសំណង់ផ្តេក
២០-វរសេនីយ៍ត្រី	**រស់**	**សោភ័ណ្ឌ**	អត្តលេខ ១៦៣២០៨	ប្រធានក្រុមកំទេចគ្រឿងផ្ទុះ
២១-វរសេនីយ៍ត្រី	**អ៊ូ**	**សុគន្ធី**	អត្តលេខ ០៤៧០៥៦	ជំនួយការបើកបររថយន្ត

p

២២-វរសេនីយ៍ត្រី	**ហោង**	**រតនា**	អត្តលេខ ០៣១៨២៩	បុគ្គលិកពេទ្យ
២៣-អនុសេនីយ៍ឯក	**សុខ**	**សុផល**	អត្តលេខ ០៨៩១១១	ប្រធានផ្នែកដឹកជញ្ជូន
២៤-អនុសេនីយ៍ឯក	**ស្ងួស**	**ឈុំ**	អត្តលេខ ០២៧១១៩	ប្រធានក្រុមបោសសំអាតមីន
២៥-អនុសេនីយ៍ឯក	**ផាន់**	**បញ្ញា**	អត្តលេខ ១០២៣៣១	បុគ្គលិកចម្រោះទឹកស្អាត
២៦-អនុសេនីយ៍ឯក	**ផាត់**	**គន**	អត្តលេខ ០៣១៣០៦	ជំនួយការទូទៅ
២៧-អនុសេនីយ៍ឯក	**ហ៊ិន**	**ម៉ិនថន**	អត្តលេខ ០១៧៩០៤	បុគ្គលិកបើកបរគ្រឿងចក្រ បោសសំអាតមីន
២៨-អនុសេនីយ៍ឯក	**សុខ**	**ពេញរឹទ្ធ**	អត្តលេខ ០៣៥២១៧	បុគ្គលិកបើកបររថយន្ត
២៩-អនុសេនីយ៍ឯក	**ពិន**	**សារ៉េត**	អត្តលេខ ០៨៧០២៨	ជំនួយការបច្ចេកទេស
៣០-អនុសេនីយ៍ឯក	**ស៊ឹម**	**សុផារ៉ា**	អត្តលេខ ០៦៥៩៨៥	ប្រធានក្រុមបោសសំអាតមីន
៣១-អនុសេនីយ៍ឯក	**ពេជ្រ**	**ចិរៈសេរី**	អត្តលេខ០៨៩២៨៥	ប្រធានផ្នែកគ្រឿងចក្រ និងជួសជុល
៣២-អនុសេនីយ៍ឯក	**ឆាយ**	**ចាន់ឆា**	អត្តលេខ ២២១២១៣	ជំនួយការត្រួតពិនិត្យគុណភាព
៣៣-អនុសេនីយ៍ទោ	**អ៊ុំ**	**កុសល្យ**	អត្តលេខ ១៦៣២០៥	ចុងភៅ
៣៤-អនុសេនីយ៍ទោ	**គង់**	**ចាន់ណាល់**	អត្តលេខ ២០០៨០៩	មេបញ្ជាការកងអនុសេនាតូច គាំទ្រផ្នែកភស្តុភារ
៣៥-អនុសេនីយ៍ទោ	**ស៊ឹម**	**គន**	អត្តលេខ ២០០៨៨៨	បុគ្គលិកបើកបររថយន្ត
៣៦-អនុសេនីយ៍ទោ	**ហ៊ឹម**	**សាខុច**	អត្តលេខ១៥៦៧១៦	ជាងសំណង់
៣៧-អនុសេនីយ៍ទោ	**ចាន់**	**សារឿន**	អត្តលេខ ១៩៨៨២៦	បុគ្គលិកបើកបរគ្រឿងចក្រ បោសសំអាតមីន
៣៨-អនុសេនីយ៍ត្រី	**សែម**	**ឡឿន**	អត្តលេខ ២០០៨៦៩	ជាងជួសជុល
៣៩-អនុសេនីយ៍ត្រី	**ឈុន**	**ឆាយ**	អត្តលេខ ១៥៧០២៧	មេបញ្ជាការកងអនុសេនាតូច ស្ថាបនាសំណង់
៤០-អនុសេនីយ៍ត្រី	**អួន**	**កុសល**	អត្តលេខ ០៨៩៥៨៥	ជាងសំណង់
៤១-អនុសេនីយ៍ត្រី	**ម៉ុត**	**យ៉ុន**	អត្តលេខ ០៦៥៦២៦	ជំនួយការអគ្គិសនី
៤២-អនុសេនីយ៍ត្រី	**សាន**	**វ៉ាន់**	អត្តលេខ ២០០៨៨៩	បុគ្គលិកបោសសំអាតមីន
៤៣-អនុសេនីយ៍ត្រី	**អ៊ុយ**	**សុផល**	អត្តលេខ ០៨៨៧៧៣	បុគ្គលិកបើកបររថយន្ត
៤៤-អនុសេនីយ៍ត្រី	**ឃី**	**គីមឿ**	អត្តលេខ ២០០៨១៥	ប្រធានផ្នែកសេវាកម្ម
៤៥-អនុសេនីយ៍ត្រី	**ទុំ**	**សំអឿន**	អត្តលេខ ០៨៩១៣០	បុគ្គលិកបើកបររថយន្ត
៤៦-អនុសេនីយ៍ត្រី	**ស៊ឹម**	**ឡឿន**	អត្តលេខ ០៨៩២២៦	បុគ្គលិកបើកបររថយន្ត
៤៧-អនុសេនីយ៍ត្រី	**ចម**	**ម៉ៅ**	អត្តលេខ ១៥៦៧១៧	បុគ្គលិកបោសសំអាតមីន

p

៤៨-អនុសេនីយ៍ត្រី	**ឌី**	**ស្រ៊ាង**	អត្តលេខ ១៦៣១៥៤	មេបញ្ជាការរងកងអនុសេនាតូច បោសសំអាតមីន និងកំទេចគ្រឿងផ្ទុះ
៤៩-នាយចំណង់	**ឈាង**	**ឫទ្ធី**	អត្តលេខ ១៨៧៩៣០	ប្រធានផ្នែកស្តាបនាសំណង់បញ្ជរ
៥០-នាយចំណង់	**ម៉ែន**	**គន្ធា**	អត្តលេខ ២១៦៣៦៨	មេបញ្ជាការរង កងវិស្វកម្មលេខ៦០៣
៥១-នាយចំណង់	**ឡោះ**	**សាហ្វីអ៊ី**	អត្តលេខ ០៧០៥៧៣	ជំនួយការវិទ្យុទាក់ទង
៥២-នាយចំណង់	**ឃី**	**សោភ័ណ្ឌ**	អត្តលេខ ០៤៩១១៧	ជំនួយការបើកបរគ្រឿងចក្រ
៥៣-នាយចំណង់	**ផាយ**	**អេន**	អត្តលេខ ០៧០២៤៦	ជំនួយការបើកបររថយន្ត
៥៤-នាយចំណង់	**សុខ**	**យឿម**	អត្តលេខ ០៦៨៧២០	បុគ្គលិកបើកបររថយន្ត
៥៥-នាយចំណង់	**ហាក់**	**ស៊ីវណ្ណារ៉ាត**	អត្តលេខ ០៥៩៤៤១	បុគ្គលិកកំទេចគ្រឿងផ្ទុះ
៥៦-ព្រិន្ទបាលឯក	**គង់**	**គា**	អត្តលេខ ០៦៩២៨៨	ចុងភៅ
៥៧-ព្រិន្ទបាលឯក	**ទ្រាំ**	**សុផល**	អត្តលេខ ០៧៩៧៧៥	បុគ្គលិកបើកបរគ្រឿងចក្រ
៥៨-ព្រិន្ទបាលឯក	**សយ**	**សុភ័ក្រ្ត**	អត្តលេខ ០៧០៦៥៤	បុគ្គលិកបើកបររថយន្ត
៥៩-ព្រិន្ទបាលឯក	**ជា**	**សំអុល**	អត្តលេខ ២២១១០៨	បុគ្គលិកបើកបររថយន្ត
៦០-ព្រិន្ទបាលឯក	**ជា**	**រិទ្ធី**	អត្តលេខ ០៧០៥៩៥	បុគ្គលិកពេទ្យ
៦១-ព្រិន្ទបាលឯក	**ខៀវ**	**ម៉ុន**	អត្តលេខ ០៦៨៧៩២	ជាងឈាប
៦២-ព្រិន្ទបាលទោ	**ភាន់**	**សារឿន**	អត្តលេខ ០៦៨៧១១	បុគ្គលិកបើកបររថយន្ត
៦៣-ព្រិន្ទបាលទោ	**ម៉ែន**	**ហៀន**	អត្តលេខ ២២១៤៥៥	ចុងភៅ
៦៤-ព្រិន្ទបាលទោ	**អ៊ឹម**	**សំ**	អត្តលេខ ១០០៨២៨	បុគ្គលិកបើកបរគ្រឿងចក្រ
៦៥-ព្រិន្ទបាលទោ	**ម៉ែន**	**សុខុម**	អត្តលេខ ១៤១៥៧៤	ជំនួយការរដ្ឋបាល
៦៦-ព្រិន្ទបាលទោ	**ហេង**	**ចាន់រិទ្ធ**	អត្តលេខ ១៤១៨៩២	ជំនួយការបច្ចេកទេស
៦៧-ព្រិន្ទបាលទោ	**យុង**	**សុផល**	អត្តលេខ ២១៧៨២២	បុគ្គលិកបើកបររថយន្ត
៦៨-ព្រិន្ទបាលទោ	**ស៊ី**	**ឃីមហួរ**	អត្តលេខ ២២១៤២៣	ជំនួយការស្រាវជ្រាវ
៦៩-ពលបាលទោ	**នាង**	**ដារ៉ា**	អត្តលេខ ២០០៨៧៧	ជំនួយការពិសោធន៍គុណភាព
៧០-ពលបាលទោ	**គីម**	**ធួន**	អត្តលេខ ២០០៨៧៣	ជាងសំណង់
៧១-ពលបាលទោ	**ស៊ាង**	**ទិទ្ធិភា**	អត្តលេខ ២០០៨៨១	ជាងឈាប
៧២-ពលបាលទោ	**លេង**	**ឈុនលី**	អត្តលេខ ២០០៩៨៣	ជាងតបណ្តាញអគ្គិសនី
៧៣-ពលបាលត្រី	**ជា**	**ចេក**	អត្តលេខ ២០០៨៧៦	បុគ្គលិកបើកបររថយន្ត
៧៤-ពលបាលត្រី	**ម៉ុន**	**សាម៉េត**	អត្តលេខ ២២១៤៣៥	បុគ្គលិកបើកបររថយន្ត
៧៥-ពលបាលត្រី	**ស៊ិន**	**សុផល**	អត្តលេខ ១៣៥៩២០	បុគ្គលិកបើកបរគ្រឿងចក្រ បោសសំអាតមីន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៥៤៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

ប្រការ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនកងឯកភាព ចំនួន ០១ គ្រឿង និងនាយទាហាន នាយទាហានរង ចំនួន ១២៨ រូប កងវិស្វកម្មលេខ៦០៣ មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាពបោសសំអាតមីន និងកាកសំណល់សង្គ្រាម ដែលមានស្នាដៃក្នុងការបំពេញបេសកកម្មសន្តិភាព របស់អង្គការសហប្រជាជាតិ នៅប្រទេសលីបង់ ដូចមានរាយនាមខាងក្រោម ៖

-ចំពោះកងឯកភាព

-កងវិស្វកម្មលេខ៦០៣

-ចំពោះបុគ្គល

១-វរសេនីយ៍ឯក	**ខិន**	**ចាន់**	អត្តលេខ ០៤៨៣៩៩	បុគ្គលិកអនាម័យ
២-វរសេនីយ៍ទោ	**ហ៊ិន**	**សុធា**	អត្តលេខ ០៣៩៧២៩	នាយសេនាធិការ កងវិស្វកម្មលេខ៦០៣

p

៣-វរសេនីយ៍ទោ	ចាន់	ដារ៉ាឧត្ត	អត្តលេខ ០១២៥១៨	បុគ្គលិកពេទ្យ
៤-វរសេនីយ៍ត្រី	ឡាង	ជីវ័ន្ត	អត្តលេខ ០៣៧៥៩៩	បុគ្គលិកបើកបររថយន្ត
៥-វរសេនីយ៍ត្រី	ខឹម	សុតេត្រា	អត្តលេខ ០៣៧៥៨៨	ជំនួយការត្រួតពិនិត្យគុណភាព
៦-អនុសេនីយ៍ឯក	ចេន	សាម៉ុន	អត្តលេខ ១៨៧៨២៧	បុគ្គលិកស្រាវជ្រាវ
៧-អនុសេនីយ៍ឯក	យ៉ាន់	សុខខេមហា	អត្តលេខ ១៦៦៤៨៧	ជំនួយការទូទៅ
៨-អនុសេនីយ៍ឯក	ស័ក្ត	សីហារិទ្ធ	អត្តលេខ ១០៨៩៣៧	មេបញ្ជាការរង កងអនុសេនាតូច ស្ថាបនាសំណង់
៩-អនុសេនីយ៍ឯក	ឡុង	សុវណ្ណា	អត្តលេខ ០៣៩៩០៩	ជាងសំណង់
១០-អនុសេនីយ៍ឯក	កែវ	សុខចំរើន	អត្តលេខ ០៤៩៦៩៧	ជាងសំណង់
១១-អនុសេនីយ៍ឯក	សៀក	សឹក	អត្តលេខ ០៣៩៩០៥	ជាងផ្សារដែក
១២-អនុសេនីយ៍ឯក	ឆាយ	មូរ៉ា	អត្តលេខ ០៤៨៤៧៦	ជាងតបណ្តាញទឹក
១៣-អនុសេនីយ៍ឯក	ផន	ភាពេជ្រ	អត្តលេខ ០៨៨៩៦២	ជំនួយការបច្ចេកទេស
១៤-អនុសេនីយ៍ឯក	ហុក	គឹមដា	អត្តលេខ ១៤៥១១០	បុគ្គលិកបោសសំអាតមីន
១៥-អនុសេនីយ៍ឯក	ប្រាក់	វណ្ណនី	អត្តលេខ ០៥៩០៦៥	បុគ្គលិកបើកបរគ្រឿងចក្រ
១៦-អនុសេនីយ៍ឯក	មាស	ស៊ីវ	អត្តលេខ ១៧៨៩៧៤	ជាងជួសជុល
១៧-អនុសេនីយ៍ឯក	អ៊ី	ស៊ីមីហៀល	អត្តលេខ ១៦៨៤៥២	បុគ្គលិកបើកបររថយន្ត
១៨-អនុសេនីយ៍ឯក	ឡេក	សារឿន	អត្តលេខ ១៦៨៤០៦	បុគ្គលិកស្រាវជ្រាវ
១៩-អនុសេនីយ៍ទោ	គង់	សំអឿន	អត្តលេខ ២២២២១៦	បុគ្គលិកបើកបររថយន្ត
២០-អនុសេនីយ៍ទោ	អ៊ុន	តារ៉ា	អត្តលេខ ២១៩៦៧៤	បុគ្គលិកបើកបររថយន្ត
២១-អនុសេនីយ៍ទោ	ម៉ម	ម៉ុនធឿន	អត្តលេខ ០៤២៣៧៨	បុគ្គលិកបោសសំអាតមីន
២២-អនុសេនីយ៍ទោ	នឿក	សម្បត្តិ	អត្តលេខ ១៣៣៥៣៦	បុគ្គលិកបើកបររថយន្ត
២៣-អនុសេនីយ៍ទោ	តេង	កង់	អត្តលេខ ០៥៩០១២	មុខងារចុងភៅ
២៤-អនុសេនីយ៍ទោ	ឡឿម	ធូ	អត្តលេខ ០៤៣៤១០	បុគ្គលិកពេទ្យ
២៥-អនុសេនីយ៍ទោ	យុទ្ធ	គីម	អត្តលេខ ០៣០១៨០	បុគ្គលិកសង្គ្រោះ
២៦-អនុសេនីយ៍ទោ	មុំ	សោភា	អត្តលេខ ២១៩៩៥២	ជំនួយការទូទៅ
២៧-អនុសេនីយ៍ទោ	សូរ្យ	ម៉ៃយ៉ាសិទ្ធ	អត្តលេខ ០២៥៥៨៨	បុគ្គលិកពេទ្យ
២៨-អនុសេនីយ៍ទោ	ហាខ្យ	ហ្វូ	អត្តលេខ ១៦៣២០៣	ប្រធានក្រុមបោសសំអាតមីន
២៩-អនុសេនីយ៍ត្រី	យ៉ាង	សាម៉ីឌី	អត្តលេខ ១៦៣៥០៩	បុគ្គលិកអនាម័យ
៣០-អនុសេនីយ៍ត្រី	ប៉ាវ	តុលា	អត្តលេខ ០៨៦៦៧៨	បុគ្គលិកពេទ្យ
៣១-អនុសេនីយ៍ត្រី	អាត់	គុណា	អត្តលេខ ០៥៣១៥២	ជាងតបណ្តាញអគ្គិសនី
៣២-អនុសេនីយ៍ត្រី	ហ៊ិន	ជីម	អត្តលេខ ១៥១៩១០	ជាងជួសជុល

៣៣-អនុសេនីយ៍ត្រី	**ព្រាប**	**ចំរើន**	អត្តលេខ ២២៨៨៨៥	បុគ្គលិកបើកបររថយន្ត
៣៤-អនុសេនីយ៍ត្រី	**កុយ**	**សម្បត្តិ**	អត្តលេខ ១៦១៥៣៩	បុគ្គលិកបើកបររថយន្ត
៣៥-អនុសេនីយ៍ត្រី	**ឌី**	**ស៊ីម**	អត្តលេខ ១៧៨៩៣៥	បុគ្គលិកបើកបររថយន្ត
៣៦-អនុសេនីយ៍ត្រី	**ជា**	**សំណឿន**	អត្តលេខ ១៣៧៧៦២	បុគ្គលិកបោសសំអាតមីន
៣៧-អនុសេនីយ៍ត្រី	**ម៉ាន់**	**សុធា**	អត្តលេខ ២០០៨១១	ប្រធានបុគ្គលិកកំទេចគ្រឿងផ្ទុះ
៣៨-អនុសេនីយ៍ត្រី	**សួន**	**រតនា**	អត្តលេខ ០៣៣៦៥៧	បុគ្គលិកបើកបររថយន្ត
៣៩-នាយចំណង់	**ឌិម**	**មួ**	អត្តលេខ ០៦៩២៨៦	បុគ្គលិកបើកបររថយន្ត
៤០-នាយចំណង់	**កែវ**	**រ៉ន្នី**	អត្តលេខ ០៥៣២៧៦	បុគ្គលិកបើកបររថយន្ត
៤១-នាយចំណង់	**ជា**	**សំអឿន**	អត្តលេខ ២២២០៤៨	បុគ្គលិកបើកបររថយន្ត
៤២-នាយចំណង់	**តន់**	**ឌីពិសិដ្ឋ**	អត្តលេខ ២១៦៣១៥	បុគ្គលិកបើកបររថយន្ត
៤៣-នាយចំណង់	**កែវ**	**សំណាង**	អត្តលេខ ២០០៧៩៨	មេបញ្ជាការ កងអនុសេនាតូចគាំទ្រផ្នែកភស្តុភារ
៤៤-នាយចំណង់	**ម៉ុន**	**សារិទ្ធ**	អត្តលេខ ០៦៨៨៣៥	ជំនួយការបច្ចេកទេស
៤៥-នាយចំណង់	**ឆាត**	**រដ្ឋា**	អត្តលេខ ០៥៩៤៥១	ជាងសំណង់
៤៦-នាយចំណង់	**ម៉ែន**	**ចម្លើយ**	អត្តលេខ ១៥៦៨៨៧	បុគ្គលិកបើកបរគ្រឿងចក្រ បោសសំអាតមីន
៤៧-នាយចំណង់	**និត្យ**	**កែវ**	អត្តលេខ ១៧៨៩៨៨	បុគ្គលិកបើកបររថយន្ត
៤៨-នាយចំណង់	**ចិន**	**សាម៉ន**	អត្តលេខ ១៦៨៨៣៧	បុគ្គលិកបើកបររថយន្ត
៤៩-នាយចំណង់	**ពៅ**	**ឧុទ្ធី**	អត្តលេខ ១៥៦៧១៥	បុគ្គលិកបោសសំអាតមីន
៥០-នាយចំណង់	**ឌុជ**	**ខឿន**	អត្តលេខ ០៨៤៦៧៨	បុគ្គលិកបោសសំអាតមីន
៥១-នាយចំណង់	**យឹន**	**ភក្តី**	អត្តលេខ ០៨៥២០៩	បុគ្គលិកបោសសំអាតមីន
៥២-នាយចំណង់	**ព្រុំ**	**សុផុន**	អត្តលេខ ១៣៧៨៥២	បុគ្គលិកកំទេចគ្រឿងផ្ទុះ
៥៣-នាយចំណង់	**ណោម**	**វណ្ណា**	អត្តលេខ ២០៦២៥០	បុគ្គលិកបើកបររថយន្ត
៥៤-នាយចំណង់	**អែម**	**សុគ័ន្ធា**	អត្តលេខ ២១៦៣៥០	ជំនួយការត្រួតពិនិត្យគុណភាព
៥៥-នាយចំណង់	**ឡឹក**	**ទីរ៉ា**	អត្តលេខ ២១៦៣៧២	បុគ្គលិកបោសសំអាតមីន
៥៦-នាយចំណង់	**អៀង**	**រដ្ឋា**	អត្តលេខ ២១៦៣៦៥	ជំនួយការទូទៅ
៥៧-នាយចំណង់	**ថន**	**សុខឿន**	អត្តលេខ ២១៦៣៥៧	ជាងសំណង់
៥៨-នាយចំណង់	**សាន**	**វណ្ណា**	អត្តលេខ ២១៦៣៥៨	ជាងសំណង់
៥៩-នាយចំណង់	**មាន**	**សំណាង**	អត្តលេខ ២១៦៣៣៨	ជាងសំណង់
៦០-នាយចំណង់	**តួច**	**ឯកខេមរៈ**	អត្តលេខ ២១៦៣៤២	ជាងសំណង់
៦១-នាយចំណង់	**រស់**	**ដានី**	អត្តលេខ ២១៦៣៧០	ជំនួយការបច្ចេកទេស

p

៦២-នាយចំណង់	គី	ដួណា	អត្តលេខ ០៨៦២៨៦	ជំនួយការរដ្ឋបាល
៦៣-ព្រិន្ទបាលឯក	យក់	គីមសៀង	អត្តលេខ ១៨៨៦៩៨	ចុងភៅ
៦៤-ព្រិន្ទបាលឯក	សួន	សាន្ត	អត្តលេខ ២០៨៨៣៥	ជាងសំណង់
៦៥-ព្រិន្ទបាលឯក	ប្រាក់	ភ្លោត	អត្តលេខ ១៥៧៣៨៥	ជាងឈើ
៦៦-ព្រិន្ទបាលឯក	ជុំ	ឌុច	អត្តលេខ ២២៦៥៨៥	ជំនួយការបច្ចេកទេស
៦៧-ព្រិន្ទបាលឯក	អ៊ុក	ផល	អត្តលេខ ០៥៩៨៥៦	ប្រធានក្រុមគ្រឿងចក្រ បោសសំអាតមីន
៦៨-ព្រិន្ទបាលឯក	ខៀវ	វណ្ណសុធា	អត្តលេខ ១៦៣៣០៩	ជំនួយការបើកបរគ្រឿងចក្រ
៦៩-ព្រិន្ទបាលឯក	ហ៊ី	លីណា	អត្តលេខ ២០៦៨២៩	ជំនួយការស្រាវជ្រាវ
៧០-ព្រិន្ទបាលឯក	តូច	តារា	អត្តលេខ ១៨៩១០០	បុគ្គលិកបោសសំអាតមីន
៧១-ព្រិន្ទបាលឯក	ហួន	ចំរើន	អត្តលេខ ១៦៣០៨៨	បុគ្គលិកបោសសំអាតមីន
៧២-ព្រិន្ទបាលឯក	រិទ្ធ	ចារិន្ទ	អត្តលេខ ១៩០៦៣១	បុគ្គលិកបោសសំអាតមីន
៧៣-ព្រិន្ទបាលឯក	ឌុយ	ធឿត	អត្តលេខ ១៦១៣០៨	បុគ្គលិកបោសសំអាតមីន
៧៤-ព្រិន្ទបាលឯក	ក្រាំ	សារេត	អត្តលេខ ០៥៥១៨៩	បុគ្គលិកបោសសំអាតមីន
៧៥-ព្រិន្ទបាលឯក	អៀម	ទី	អត្តលេខ ០៧២១៨២	បុគ្គលិកបោសសំអាតមីន
៧៦-ព្រិន្ទបាលឯក	ធឿត	ធឿង	អត្តលេខ ២១៨៧៥៦	បុគ្គលិកបោសសំអាតមីន
៧៧-ព្រិន្ទបាលឯក	នេត	សំអឿន	អត្តលេខ ២២១២៤០	បុគ្គលិកបោសសំអាតមីន
៧៨-ព្រិន្ទបាលទោ	មុំ	កុល្លីណា	អត្តលេខ ១៩០៧៧៧	ជាងឈើ
៧៩-ព្រិន្ទបាលទោ	ហាក់	ហួន	អត្តលេខ ១៨៣៨៥៥	ជាងសំណង់
៨០-ព្រិន្ទបាលទោ	ម៉េត	សុផល	អត្តលេខ ០៦៩៣១៦	ជំនួយការបើកបរគ្រឿងចក្រ
៨១-ព្រិន្ទបាលទោ	ពុធ	ឡោ	អត្តលេខ ១០៣៧១៨	បុគ្គលិកបោសសំអាតមីន
៨២-ពលបាលឯក	ព្រឿង	ឌុទ្ធី	អត្តលេខ ១០៥១៩០	ជំនួយការទូទៅ
៨៣-ពលបាលឯក	កាំង	វណ្ណ	អត្តលេខ ០៨៨៨៨២	បុគ្គលិកកំទេចគ្រឿងផ្ទុះ
៨៤-ពលបាលឯក	ម៉ុក	ឈិនឡុង	អត្តលេខ ២១៨៥១៨	បុគ្គលិកបើកបររថយន្ត
៨៥-ពលបាលឯក	គ្រឹង	គីឡា	អត្តលេខ ១៥១៥៦៣	បុគ្គលិកបោសសំអាតមីន
៨៦-ពលបាលទោ	ឌី	សុខុន	អត្តលេខ ២០០៩៨៨	បុគ្គលិកកំទេចគ្រឿងផ្ទុះ
៨៧-ពលបាលទោ	ហ៊ីន	ច័ន្ទធីរៈ	អត្តលេខ ០៨០៨៨៦	ជំនួយការទូទៅ
៨៨-ពលបាលទោ	សឿន	ចំរឿន	អត្តលេខ ២០១០១៧	ជាងសំណង់
៨៩-ពលបាលទោ	ណាន	ឡឿន	អត្តលេខ ២០០៨៩៦	បុគ្គលិកបើកបររថយន្ត

៩០-ពលបាលទោ	**អយ**	**ច័ន្ទតារា**	អត្តលេខ ២០០៩៥៦	បុគ្គលិកបើកបររថយន្ត
៩១-ពលបាលទោ	**សឿន**	**ឌីណា**	អត្តលេខ ២០០៨៨៦	បុគ្គលិកបើកបររថយន្ត
៩២-ពលបាលទោ	**ណោន**	**សុវណ្ណារ៉ា**	អត្តលេខ ២០០៩៧៩	បុគ្គលិកបោសសំអាតមីន
៩៣-ពលបាលទោ	**ឡៀង**	**គីមស្រៀង**	អត្តលេខ ២០០៩៣៨	បុគ្គលិកបើកបរគ្រឿងចក្រ
៩៤-ពលបាលទោ	**ថ៉ាន់**	**ចាន់ថន**	អត្តលេខ ២០០៩៧៨	បុគ្គលិកបើកបររថយន្ត
៩៥-ពលបាលទោ	**អ៊ុក**	**គីមសាន**	អត្តលេខ ២០០៩៩៧	ចុងភៅ
៩៦-ពលបាលទោ	**ប្រាក់**	**សំណាង**	អត្តលេខ ២០០៩២៨	បុគ្គលិកបើកបរគ្រឿងចក្រ បោសសំអាតមីន
៩៧-ពលបាលទោ	**ហឿង**	**ឧត្តី**	អត្តលេខ ២១១០១០	សន្តិសុខ
៩៨-ពលបាលទោ	**សេង**	**បូរី**	អត្តលេខ ២០០៩០៣	សន្តិសុខ
៩៩-ពលបាលទោ	**ជន**	**ចាន់ថា**	អត្តលេខ ២០០៩៥៨	បុគ្គលិកស្រាវជ្រាវ
១០០-ពលបាលទោ	**អ៊ុំ**	**សុគិរះ**	អត្តលេខ ២០០៨៦៧	ជំនួយការទូទៅ
១០១-ពលបាលទោ	**ម៉ៅ**	**ផល្លី**	អត្តលេខ ២០០៩៩៨	ជាងសំណង់
១០២-ពលបាលទោ	**ឈឹម**	**តូ**	អត្តលេខ ២០០៩១១	ជាងសំណង់
១០៣-ពលបាលទោ	**ឈន**	**ម៉ឺន**	អត្តលេខ ២០០៩១៦	ជាងតបណ្តាញទឹក
១០៤-ពលបាលទោ	**ម៉ុំ**	**តុលា**	អត្តលេខ ២០០៨៣៩	បុគ្គលិកបើកបរគ្រឿងចក្រ
១០៥-ពលបាលទោ	**លេន**	**ចាន់ណារ៉ា**	អត្តលេខ ២០១០០០	ជំនួយការបើកបរគ្រឿងចក្រ
១០៦-ពលបាលទោ	**នង**	**ហ្វយ**	អត្តលេខ ២០០៩១២	បុគ្គលិកបើកបររថយន្ត
១០៧-ពលបាលទោ	**ខាត់**	**ម៉ិនឡើម**	អត្តលេខ ២០០៩០១	បុគ្គលិកបើកបររថយន្ត
១០៨-ពលបាលទោ	**អ៊ុក**	**គីមសឿន**	អត្តលេខ ២០០៩៨១	បុគ្គលិកចម្រោះទឹកស្អាត
១០៩-ពលបាលទោ	**សែម**	**ភក្តដា**	អត្តលេខ ២២១៣៧	ជាងជួសជុល
១១០-ពលបាលត្រី	**ហុង**	**សាឌុធ**	អត្តលេខ ២០០០៩៦០	បុគ្គលិកកំទេចគ្រឿងផ្ទុះ
១១១-ពលបាលត្រី	**អ៊ីន**	**ចាន់ធី**	អត្តលេខ ២០១០១៩	បុគ្គលិកបើកបររថយន្ត
១១២-ពលបាលត្រី	**អាន**	**សេងហៀង**	អត្តលេខ ២០១០០៤	ជំនួយការបច្ចេកទេស
១១៣-ពលបាលត្រី	**ចាន់**	**ឡូត**	អត្តលេខ ២០០៨៦១	បុគ្គលិកបើកបររថយន្ត
១១៤-ពលបាលត្រី	**ចក់**	**ស៊ីត់ត្រា**	អត្តលេខ ២០០៩៥១	បុគ្គលិកកំទេចគ្រឿងផ្ទុះ
១១៥-ពលបាលត្រី	**ប្រាក់**	**ម៉ន**	អត្តលេខ ២០០៩២៣	បុគ្គលិកកំទេចគ្រឿងផ្ទុះ
១១៦-ពលបាលត្រី	**យូ**	**សារ៉េត**	អត្តលេខ ២០០៨៥៦	ជាងសំណង់

p

១១៧-ពលបាលត្រី	អ៊ុំ	សុខឡេង	អត្តលេខ ២២៦៣៣៩	ជាងសំណង់
១១៨-ពលបាលត្រី	ម៉ែន	ទិដ្ឋិភា	អត្តលេខ ២០០៨៩៣	បុគ្គលិកបើកបររថយន្ត
១១៩-ពលបាលត្រី	ទ៉ាន់	សឿប	អត្តលេខ ២០០៨៥៩	ជំនួយការបើកបរគ្រឿងចក្រ
១២០-ពលបាលត្រី	សោម	ចិត្រា	អត្តលេខ ២០០៨៤៨	បុគ្គលិកបោសសំអាតមីន
១២១-ពលបាលត្រី	ជុំ	សារឿន	អត្តលេខ ២០០៨៥០	បុគ្គលិកបោសសំអាតមីន
១២២-ពលបាលត្រី	ហេង	សុខហឿន	អត្តលេខ ២០០៨០៨	បុគ្គលិកបោសសំអាតមីន
១២៣-ពលបាលត្រី	ប្រាក់	ទ៉ាត	អត្តលេខ ១០២៨៤១	បុគ្គលិកបោកអ៊ុត
១២៤-ពលបាលត្រី	នេត	ជាណារ៉ុម	អត្តលេខ ២២៦៣៥២	ជាងជួសជុល
១២៥-ពលបាលត្រី	ឈន់	ស្មើ	អត្តលេខ ២២៦៣៤៥	ជំនួយការបើកបរគ្រឿងចក្រ
១២៦-នាយឯក	ដួង	ត្រឹម	អត្តលេខ ១០២៣៥៥	ជាងផ្សារដែក
១២៧-នាយឯក	ថ្លៃ	សាវេន	អត្តលេខ ១១០៣២៦	បុគ្គលិកកំទេចគ្រឿងផ្ទុះ
១២៨-នាយឯក	ឡឹក	ចិន្តា	អត្តលេខ ១១២៥៥៨	បុគ្គលិកបើកបរគ្រឿងចក្រ

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ....០៣...សសរ

សេចក្តីសម្រេច
ស្តីពី
ការតែងតាំងសមាសភាពគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកែសម្រួលគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

ប្រការ ១.-

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ដូចខាងក្រោម៖

០១-ឯកឧត្តម	**អ៊ិត សំហេង**	រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	ប្រធាន
០២-ឯកឧត្តម	**វង សូត**	រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	អនុប្រធាន
០៣-ឯកឧត្តម	**ឈូន ដារ៉ា**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	អនុប្រធាន

០៤-ឯកឧត្តម	**ទុំ សម្បុរ**	រដ្ឋលេខាធិការក្រសួងការពារជាតិ	អនុប្រធាន
០៥-ឯកឧត្តម	**ព្រុំ សុខា**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
០៦-ឯកឧត្តម	**ស្វាយ ស៊ីថា**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
០៧-ឯកឧត្តម	**នេត សាវឿន**	អគ្គស្នងការនគរបាលជាតិ	អនុប្រធាន
០៨-ឯកឧត្តម	**សៅ សុខា**	អគ្គមេបញ្ជាការរង និងជាមេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស	អនុប្រធាន
០៩-ឯកឧត្តម	**កែប ជុតិមា**	អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ	អនុប្រធាន
១០-ឯកឧត្តម	**ហ៊ីង ប៊ុនហៀង**	នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី	អនុប្រធាន
១១-ឯកឧត្តម	**សយ ស៊ីផុន**	រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	អនុប្រធានប្រចាំការ
១២-ឯកឧត្តម	**សុខចិន្តា សោភា**	អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
១៣-ឯកឧត្តម	**សួរ ឌិចឆ័រ**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១៤-ឯកឧត្តម	**ឆាន់ សាផាន**	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
១៥-ឯកឧត្តម	**គោគ សុវណ្ណារិទ្ធ**	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១៦-ឯកឧត្តម	**ពិត ចំណាន**	រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១៧-ឯកឧត្តម	**សូ ម៉ារ៉ា**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	សមាជិក
១៨-ឯកឧត្តម	**ខ្លោក ផន**	រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា	សមាជិក
១៩-ឯកឧត្តម	**អ៊ុំ មាន**	រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
២០-ឯកឧត្តម	**ប៉ាល់ ចន្ទតារា**	មេធាវីរាជរដ្ឋាភិបាល	សមាជិក
២១-ឯកឧត្តម	**ឃួន វ៉ានីន**	អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
២២-ឯកឧត្តម	**ឆាយ វណ្ណា**	អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
២៣-ឯកឧត្តម	**សាត សមុទ្រ**	អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
២៤-ឯកឧត្តម	**ឈុន ស៊ីរុន**	អភិបាលនៃគណៈអភិបាលខេត្តកណ្តាល	សមាជិក
២៥-ឯកឧត្តម	**លី ច័ន្ទតុលា**	សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
២៦-ឯកឧត្តម	**កែវ សុខសិទ្ធិនី**	ទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
២៧-ឯកឧត្តម	**កើត ឿន**	ទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក

២៨-ឯកឧត្តម	**ម៉ក់ សុតី**	ទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
២៩-ឯកឧត្តម	**ខង្យ ខណ្ណា**	ទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
៣០-ឯកឧត្តម	**សៀងសុឈុនឌី**	ទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាអគ្គនាយករងកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ	សមាជិក
៣១-ឯកឧត្តម	**សឹង ម៉ុន**	ទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
៣២-ឯកឧត្តម	**សេង សក្តា**	អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
៣៣-ឯកឧត្តម	**ឡៀង សុគន្ធ**	អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
៣៤-ឯកឧត្តម	**សំហេង បុរស**	អគ្គាធិការនៃអគ្គាធិការដ្ឋាននៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
៣៥-ឯកឧត្តម	**មាន សុតា**	ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម	សមាជិក
៣៦-ឯកឧត្តម	**ជួន សុខណ្ណា**	អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ	សមាជិក
៣៧-លោក	**សិទ្ធ សារឿន**	នាយករង នាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ	សមាជិក
៣៨-លោក	**កែវ មាស**	នាយការិយាល័យទី២ បញ្ជាការដ្ឋានកងទ័ពជើងគោក ក្រសួងការពារជាតិ	សមាជិក
៣៩-លោក	**គឹម ហុង**	អគ្គនាយកស្តីទីនៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
៤០-លោក	**គៀត ច័ន្ទថារិទ្ធ**	ប្រធានសេនាធិការ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ	សមាជិក
៤១-លោក	**តែ ស៊ីណារិទ្ធ**	ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ	សមាជិក
៤២-លោក	**ថោង លីម**	ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ	សមាជិក
៤៣-លោក	**មួន សារ៉ែន**	ប្រធានអង្គភាពអន្តរាគមន៍ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ	សមាជិក

៤៤-លោក	**ឃុន សំបូរ**	ប្រធាននាយកដ្ឋានចារកម្ម អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ	សមាជិក
៤៥-លោក	**អ៊ាច ចំរើន**	ស្នងការនគរបាលខេត្តកណ្តាល អគ្គស្នងការដ្ឋាន នគរបាលជាតិ នៃក្រសួងមហាផ្ទៃ	សមាជិក
៤៦-លោក	**អ៊ុន ខេមរា**	ប្រធាននាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
៤៧-លោក	**កុយ តេពដារាវុធ**	ប្រធាននាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
៤៨-លោក	**អ៊ុក សមវិទ្យា**	នាយកបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
៤៩-អភិបាលនៃគណៈអភិបាលខេត្តពាក់ព័ន្ធ			សមាជិក
៥០-ឯកឧត្តម	**ប្រាក់ ចាន់ធឿន**	អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មការ សម្រាប់ដោះស្រាយបញ្ហាតូដកម្ម បាតុកម្មនៅតាម គ្រប់មុខសញ្ញា	សមាជិកប្រចាំការ។

ប្រការ ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងសាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មករា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩៩៣ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

ប្រកាសរួម
ស្តីពី
ការផ្តល់សេវាសាធារណៈរបស់ក្រសួងសុខាភិបាល

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល

- បានឃើញអនុក្រឹត្យលេខ១២២ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងគ្រឿងសម្ភារៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ :

អនុញ្ញាតឱ្យក្រសួងសុខាភិបាល អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

ប្រការ ២ :

ក្រសួងសុខាភិបាល ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងសុខាភិបាល ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

ប្រការ ៣ :

ក្រសួងសុខាភិបាល មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

ប្រការ ៤ :

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាលនៃក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ ក្រសួងសុខាភិបាល ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

ប្រការ ៥ :

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ ៦ :

ក្រសួងសុខាភិបាល ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលាតាមការកំណត់។

ប្រការ ៧ :

ក្រសួងសុខាភិបាល ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

ប្រការ ៨ :

កម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាសរួម។

ប្រការ ៩ :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១០ :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះឱ្យ មានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ម៉ម ប៊ុនហេង

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»
- ដូចប្រការ ១០ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ
ភ្ជាប់នឹងប្រកាសរួមលេខ ៩៩៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២
ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសុខាភិបាល

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
1	ការផ្តល់សេចក្តីសម្រេចអនុញ្ញាតដល់គ្រឹះស្ថានផលិតឱសថ ចំពោះ ៖			
	- ការបើកថ្មី	4,000,000	20ថ្ងៃ	2ឆ្នាំ
	- ការប្តូរទីតាំង	4,000,000	20ថ្ងៃ	2ឆ្នាំ
	- ការប្តូរឱសថការី	2,000,000	20ថ្ងៃ	2ឆ្នាំ
2	ការផ្តល់វិញ្ញាបនបត្រ GMP	1,000,000	30-60ថ្ងៃ	2ឆ្នាំ
3	ការផ្តល់សេចក្តីសម្រេចអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្ម ចំពោះ ៖			
3.1	ឱសថ:			
	- តាមទស្សនាវដ្តី, សារព័ត៌មាន,ខិតប័ណ្ណ ឬប្រតិទិន	400,000	20ថ្ងៃ	1ឆ្នាំ
	- តាមទូរទស្សន៍, វិទ្យុ	600,000	20ថ្ងៃ	៦ខែ
	- តាមរយៈការធ្វើសិក្ខាសាលា ឬការប្រជុំផ្សេងៗ	600,000	7ថ្ងៃ	៦ខែ
3.2	គ្រឿងសម្អាង:			
	- តាមទស្សនាវដ្តី, សារព័ត៌មាន, ខិតប័ណ្ណ, អាហ្វីស, Poster Stand, ឯកសារផ្សព្វផ្សាយផ្សេងៗ សម្ភារៈប្រើប្រាស់ផ្សេងៗ ឬមធ្យោបាយដឹកជញ្ជូនផ្សេងៗ	400,000	20ថ្ងៃ	៦ខែ
	- តាមប្រតិទិន	400,000	20ថ្ងៃ	1ឆ្នាំ
	- តាមទូរទស្សន៍, វិទ្យុ	600,000	20ថ្ងៃ	៦ខែ

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
	- តាមប្រអប់ភ្លើងនៅតាមទីសាធារណៈ	800,000	20ថ្ងៃ	1ឆ្នាំ
	- តាមផ្ទាំងប៉ាណូ	1,000,000	20ថ្ងៃ	1ឆ្នាំ
	- តាមរយៈការធ្វើសិក្ខាសាលា ឬការប្រជុំផ្សេងៗ	600,000	7ថ្ងៃ	៦ខែ
3.3	ផលិតផលចិញ្ចឹមកុមារ និងទារកៈ			
	- តាមទស្សនាវដ្តី, សារព័ត៌មាន, ខិតប័ណ្ណ, ប្រតិទិន, អាហ្វីស, Poster Stand, ឯកសារផ្សព្វផ្សាយផ្សេងៗ, សម្ភារៈប្រើប្រាស់ផ្សេងៗ, ឬ មធ្យោបាយដឹកជញ្ជូនផ្សេងៗ	400,000	20ថ្ងៃ	1ឆ្នាំ
	- តាមទូរទស្សន៍, វិទ្យុ	600,000	20ថ្ងៃ	1ឆ្នាំ
	- តាមផ្ទាំងប៉ាណូ	1,000,000	20ថ្ងៃ	1ឆ្នាំ
3.4	ផលិតផលចិញ្ចឹមកុមារ និងទារក តាមការធ្វើសិក្ខាសាលា ឬប្រជុំផ្សេងៗ			
	- អ្នកចូលរួមត្រឹម 100នាក់	600,000	20ថ្ងៃ	តាមការស្នើសុំ
	- អ្នកចូលរួមច្រើនជាង100នាក់	1,000,000	20ថ្ងៃ	តាមការស្នើសុំ
3.5	បិទស្លាកសញ្ញាផលិតផល ឬបោះពុម្ពជាប់កំប៉ុង ឬដប	800,000	20ថ្ងៃ	3ឆ្នាំ
4	ការផ្តល់សេចក្តីសម្រេចអនុញ្ញាតឱ្យចុះពាណិជ្ជនាមឱសថ	280,000	20ថ្ងៃ	1ឆ្នាំ
5	ការផ្តល់វិញ្ញាបនបត្រឱ្យចុះបញ្ជីគ្រឹះស្ថានផលិតឱសថនៅបរទេស	4,800,000	3-6ខែ	5ឆ្នាំ
6	ការផ្តល់វិញ្ញាបនបត្រឱ្យចុះទិដ្ឋាការ-បញ្ជិកា			
6.1	ឱសថ	1,000,000	6-8ខែ	5ឆ្នាំ
6.2	បរិក្ខារពេទ្យ, ប្រតិករ, ឱសថបុរាណ, ឱសថបំប៉នសុខភាព ឬផលិតផលជំនួយសុខភាពប្រើលើខ្លួនមនុស្សខាងក្រៅ	300,000	3-4ខែ	3ឆ្នាំ

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
7	ការផ្តល់វិញ្ញាបនបត្រឱ្យចុះប្រវេទន៍គ្រឿងសម្អាង	80,000	15ថ្ងៃ	2ឆ្នាំ
8	ការផ្តល់សេចក្តីសម្រេចអនុញ្ញាតដល់គ្រឹះស្ថានអាហារ៍ណ នីហារ៍ណឱសថ គ្រឿងសម្អាង ចំពោះ ៖			
	- ការបើកថ្មី	1,200,000	15ថ្ងៃ	2ឆ្នាំ
	- ប្តូរទីតាំង	800,000	15ថ្ងៃ	2ឆ្នាំ
	- ការបើកសាខា	800,000	15ថ្ងៃ	2ឆ្នាំ
	- ប្តូរទីតាំងសាខា	600,000	15ថ្ងៃ	2ឆ្នាំ
	- ផ្លាស់ប្តូរឱសថការី	400,000	15ថ្ងៃ	2ឆ្នាំ
9	ការផ្តល់លិខិតអនុញ្ញាតឱ្យនាំចូលឱសថ -គ្រឿងសម្អាង	200,000	15ថ្ងៃ	2ឆ្នាំ
10	ការផ្តល់សេចក្តីសម្រេចអនុញ្ញាតដល់មជ្ឈមណ្ឌលថែរក្សាសម្ផស្ស ចំពោះ ៖			
	- ការបើកថ្មី	800,000	15ថ្ងៃ	2ឆ្នាំ
	- ការបើកសាខា	600,000	15ថ្ងៃ	2ឆ្នាំ
	- ប្តូរទីតាំង (គ្រឹះស្ថាន និងសាខា)	400000	15ថ្ងៃ	
11	ការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យផលិតផលម្ហូបអាហារ	500,000	40ថ្ងៃ	តាមលេខឡូត៍
12	ការផ្តល់វិញ្ញាបនបត្របញ្ជាក់កម្រិតអនាម័យតាមភោជនីយដ្ឋាន (តាមគោលការណ៍ស្ម័គ្រចិត្ត)			
	- Logo A	800,000	30ថ្ងៃ	2ឆ្នាំ
	- Logo B	600,000	30ថ្ងៃ	2ឆ្នាំ
	- Logo C	400,000	30ថ្ងៃ	2ឆ្នាំ

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
13	ការផ្តល់លិខិតអនុញ្ញាតដល់មន្ទីរព្យាបាលជម្ងឺមាត់-ធ្មេញ ចំពោះ ៖			
	- ការបើកថ្មី	4,000,000	20ថ្ងៃ	4ឆ្នាំ
	- ការផ្ទេរម្ចាស់និធិ	2,000,000	20ថ្ងៃ	
	- ការប្តូរទីតាំង	3,000,000	20ថ្ងៃ	4ឆ្នាំ
14	ការផ្តល់លិខិតអនុញ្ញាតដល់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ ចំពោះ ៖			
	- ការបើកថ្មី	4,000,000	20ថ្ងៃ	4ឆ្នាំ
	- ការផ្ទេរម្ចាស់និធិ	2,000,000	20ថ្ងៃ	
	- ការប្តូរទីតាំង	3,000,000	20ថ្ងៃ	4ឆ្នាំ
15	ការផ្តល់លិខិតអនុញ្ញាតដល់មន្ទីរសម្ភព ចំពោះ ៖			
	- ការបើកថ្មី	4,000,000	20ថ្ងៃ	4ឆ្នាំ
	- ការផ្ទេរម្ចាស់និធិ	2,000,000	20ថ្ងៃ	
	- ការប្តូរទីតាំង	3,000,000	20ថ្ងៃ	4ឆ្នាំ
16	ការផ្តល់លិខិតអនុញ្ញាតដល់មន្ទីរសម្រាកព្យាបាល ចំពោះ ៖			
	- ការបើកថ្មី	4,000,000	20ថ្ងៃ	4ឆ្នាំ
	- ការផ្ទេរម្ចាស់និធិ	2,000,000	20ថ្ងៃ	
	- ការប្តូរទីតាំង	3,000,000	20ថ្ងៃ	4ឆ្នាំ

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
17	ការផ្តល់លិខិតអនុញ្ញាតដល់មន្ទីរពេទ្យព្យាបាល ចំពោះ ៖			
	- ការបើកថ្មី	4,600,000	20ថ្ងៃ	4ឆ្នាំ
	- ការផ្ទេរម្ចាស់និធិ	2,300,000	20ថ្ងៃ	
	- ការប្តូរទីតាំង	3,000,000	20ថ្ងៃ	4ឆ្នាំ
18	ការផ្តល់លិខិតអនុញ្ញាតដល់មន្ទីរពេទ្យឯកជន ចំពោះ ៖			
	- ការបើកថ្មី	6,000,000	20ថ្ងៃ	4ឆ្នាំ
	- ការផ្ទេរម្ចាស់និធិ	3,000,000	20ថ្ងៃ	
	- ការប្តូរទីតាំង	4,000,000	20ថ្ងៃ	4ឆ្នាំ
19	ការផ្តល់លិខិតអនុញ្ញាតដល់មជ្ឈមណ្ឌលកែសម្ផស្ស ចំពោះ ៖			
	- ការបើកថ្មី	6,000,000	20ថ្ងៃ	2ឆ្នាំ
	- ការផ្ទេរម្ចាស់និធិ	3,000,000	20ថ្ងៃ	2ឆ្នាំ
	- ការប្តូរទីតាំង	4,000,000	20ថ្ងៃ	2ឆ្នាំ
20	ការផ្តល់លិខិតអនុញ្ញាតដល់ការិយាល័យទំនាក់ទំនងសេវាសុខភាព ចំពោះ ៖			
	- ការបើកថ្មី	1,000,000	20ថ្ងៃ	2ឆ្នាំ
	- ការផ្ទេរម្ចាស់និធិ	500,000	20ថ្ងៃ	
	- ការប្តូរទីតាំង	មិនគិតថ្លៃ	20ថ្ងៃ	
21	ការផ្តល់លិខិតអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្មសម្រាប់ទីតាំងប្រកបអាជីវកម្មសេវាសុខភាព និងថែរក្សា/កែសម្ផស្ស	800,000	20ថ្ងៃ	1ឆ្នាំ

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
22	ការផ្តល់លិខិតអនុញ្ញាតឱ្យចុះបញ្ជិការរថយន្តគិលានសង្គ្រោះឯកជន	100,000	5ថ្ងៃ	1ឆ្នាំ
23	ការចេញវិញ្ញាបនបត្របញ្ជាក់សុខភាព	20,000	3ថ្ងៃ	
24	ការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើសិក្ខាសាលា(ក្រៅពីផលិតផលចិញ្ចឹមកុមារ និងទារក)	មិនគិតថ្លៃ	20ថ្ងៃ	
25	ការផ្តល់លិខិតអនុញ្ញាតដល់បន្ទប់ថែទាំជម្ងឺ ឬបន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះ ឬបន្ទប់ព្យាបាលដោយចលនា ឬបន្ទប់ពិគ្រោះជម្ងឺទូទៅ ឬបន្ទប់ពិគ្រោះព្យាបាលជម្ងឺមាត់ធ្មេញ ចំពោះ ៖			
	- ការបើកថ្មី	200,000	7ថ្ងៃ	3ឆ្នាំ
	- ការប្តូរទីតាំង	មិនគិតថ្លៃ	7ថ្ងៃ	3ឆ្នាំ
26	ការផ្តល់លិខិតអនុញ្ញាតដល់ឱសថស្ថាន ចំពោះ ៖			
	- ការបើកថ្មី	600,000	7ថ្ងៃ	3ឆ្នាំ
	- ការប្តូរទីតាំង	300,000	15ថ្ងៃ	2ឆ្នាំ
	- ប្តូរឈ្មោះឱសថការី	300,000	15ថ្ងៃ	2ឆ្នាំ
27	ការផ្តល់លិខិតអនុញ្ញាតដល់ឱសថស្ថានរង "ក" ចំពោះ ៖			
	- ការបើកថ្មី	400,000	15ថ្ងៃ	2ឆ្នាំ
	- ការប្តូរទីតាំង	200,000	15ថ្ងៃ	2ឆ្នាំ
	- ប្តូរឈ្មោះឱសថការី	200,000	15ថ្ងៃ	2ឆ្នាំ
28	ការផ្តល់លិខិតអនុញ្ញាតដល់ឱសថស្ថានរង "ខ" ចំពោះ ៖			
	- ការបន្តសុពលភាព	200,000	15ថ្ងៃ	2ឆ្នាំ

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
29	ការផ្តល់លិខិតអនុញ្ញាតដល់អគារឱសថបុរាណ ចំពោះ ៖			
	- ការបើកថ្មី	400,000	15ថ្ងៃ	1ឆ្នាំ
	- ការប្តូរទីតាំង	200,000	15ថ្ងៃ	1ឆ្នាំ
	- ប្តូរឈ្មោះគ្រូឱសថបុរាណ	200,000	15ថ្ងៃ	1ឆ្នាំ
30	ត្រួតពិនិត្យ៖ -លិខិតប្រកាសទូទៅ -លក្ខណៈអនាម័យទូទៅ និងចេញលិខិតអនុញ្ញាត (សេរីប្រតិបត្តិ) ចំពោះនាវា ឬសាឡាង់ចូល	80,000	ភ្លាមៗ	ដល់ពេលចេញដំណើរ
31	ត្រួតពិនិត្យ៖ -លិខិតប្រកាសទូទៅ -លក្ខណៈអនាម័យទូទៅ និងចេញលិខិតអនុញ្ញាត ចំពោះនាវា ឬសាឡាង់ចេញ	80,000	ភ្លាមៗ	រហូតដល់កំពង់ផែបន្ទាប់
32	ធ្វើអធិការកិច្ចអនាម័យទូទៅលើនាវា ឬសាឡាង់ និងចេញវិញ្ញាបនបត្របញ្ជាក់	400,000	1-2ថ្ងៃ	6ខែ
33	ត្រួតពិនិត្យ និងចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដឹកសាកសព ឬអដ្ឋិធាតុ ឆ្លងដែនចេញ	មិនគិតថ្លៃ	30 ទៅ 60នាទី	
34	ការបណ្តុះបណ្តាលអនាម័យចំណីអាហារដល់ចុងភៅ អ្នកគ្រប់គ្រង ក្នុងភោជនីយដ្ឋាន និងក្នុងសេវាធ្វើម្ហូបការ ម្ហូបបុណ្យ និងពិធីផ្សេងៗ(គិតម្នាក់ៗ)	40,000	តាមជាក់ស្តែង	អចិន្ត្រៃយ៍
35	ផ្តល់លិខិតគាំទ្រដល់អង្គភាពក្រៅរដ្ឋាភិបាល(ចំពោះគម្រោងដែលមានថវិកាលើសពី 1ម៉ឺនដុល្លាអាមេរិក)	មិនគិតថ្លៃ	15ថ្ងៃ	1ឆ្នាំ
36	ការបកប្រែបរិយាយប័ណ្ណឱសថ	200,000	120ថ្ងៃ	អចិន្ត្រៃយ៍
37	ការផ្តល់លិខិតអនុញ្ញាតជូនគម្រោងសិក្សាស្រាវជ្រាវ	1,600,000	60-90ថ្ងៃ	ឆ្នាំ

ល.រ	បរិយាយ	តម្លៃសេវា (រៀល)	រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
38	ការផ្ដល់វិញ្ញាបនបត្របញ្ជាក់អនាម័យចំណីអាហារ			
	- តាមភោជណីយដ្ឋានខ្នាតធំ និងប្រណិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា	600,000	20ថ្ងៃ	1ឆ្នាំ
	- តាមអាហារដ្ឋានខ្នាតធំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា	600,000	20ថ្ងៃ	1ឆ្នាំ
	- តាមភោជណីយដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា	400,000	20ថ្ងៃ	1ឆ្នាំ
	- តាមអាហារដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា	400,000	20ថ្ងៃ	1ឆ្នាំ

សេចក្ដីបញ្ជាក់:

- រាល់ការស្នើសុំបិទ ឈប់ ឬលុបសេវានានា (រួមទាំងលេខទិដ្ឋាការ) ដែលមានក្នុងតារាងឧបសម្ព័ន្ធខាងលើ ក្រសួង/មន្ទីរសុខាភិបាល នឹងផ្ដល់ជូនក្នុងរយៈពេល 15ថ្ងៃ ដោយមិនគិតថ្លៃ។
- រាល់ការស្នើសុំបន្តសុពលភាព ឬបន្តសេចក្ដីសម្រេចដែលមានក្នុងឧបសម្ព័ន្ធនេះ ក្រសួង/មន្ទីរសុខាភិបាល កំណត់យកតម្លៃ 70% នៃតម្លៃសេវាដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនេះ។ សុពលភាពបន្ត មានរយៈពេលស្មើនឹងសុពលភាពផ្ដល់ជូនដំបូងដែរ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៩៩៤...សហវ.ក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

ប្រកាសរួម
ស្តីពី
ការផ្តល់របាទ់លើកទឹកចិត្តជូន
ក្រសួងសុខាភិបាល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
Phnom Penh CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ១២២ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងគ្រឿងសម្ភារ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ស ម្រេ ច

ប្រការ ១ :

អនុញ្ញាតឱ្យក្រសួងសុខាភិបាល អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

ប្រការ ២ :

ក្រសួងសុខាភិបាល ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងសុខាភិបាល ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

ប្រការ ៣ :

ក្រសួងសុខាភិបាល មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

ប្រការ ៤ :

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងសុខាភិបាល តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរសុខាភិបាលរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ

ប្រការ ៥ :

រដ្ឋបាលកណ្តាលនៃក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលនៃក្រសួងសុខាភិបាល ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងសុខាភិបាលដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ (ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងសុខាភិបាលត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។
